# សំណើប្រជាមតិ 39 លក្ខខ័ណ្ឌពន្ធដារ សំរាប់ពាណិជ្ជកម្មពហុហុរដ្ឋ។ ការផ្តល់ថវិកាសំរាប់ថាមពលល្អស្អាត និងថាមពលបរិបូរណ៍។ លក្ខន្តិកៈផ្តួចផ្តើម។

## ★ ទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 39 ★

ក្នុងឆ្នាំ 2009,ការព្រមព្រៀងនយោបាយមួយបានបង្កើតច្បាប់បញ្ចៀសពន្ធប្រហែលមួយរយកោដិដុល្លារសំរាប់សាជីវកម្មក្រៅរដ្ឋ . . .

ការចរចាពីថវិកានៅចុងឆ្នាំ 2009 នៅ Sacramento នៅពាក់ កណ្តាលអធ្រាត្យ ក្រុមអ្នកបង្កើតច្បាប់ និងអ្នកបញ្ចុះបញ្ចូលរបស់សាជីវកម្មសំរាប់ក្រុមហ៊ុននៅក្រៅរដ្ឋបានធ្វើកិច្ចព្រមព្រៀងមួយ -ដោយគ្មានសវនាការសាធារណៈនិងការពិភាក្សាវែកញែកទេ។ ពួកគេដាក់ឲ្យមានការបញ្ចៀសពន្ធនៅក្នុងច្បាប់រដ្ឋដែលអនុញ្ញាតឲ្យសាជីវកម្មដែលនៅក្រៅរដ្ឋអាចបន្លំប្រព័ន្ធពន្ធដាររបស់យើងជារៀងរាល់ឆ្នាំ ហើយចៀសវាងការបង់ពន្ធភាគលាភស្មើគ្នារបស់ពួកគេទៅឲ្យរដ្ឋកាលីហ្វ័រញ៉ា។

តម្លៃនៃការបញ្ចៀសពន្ធនៃច្បាប់នេះមាន៖ $1 មួយរយកោដិដុល្លារក្នុងមួយឆ្នាំលើប្រាក់ចំណូលដែលបាត់បង់សម្រាប់រដ្ឋកាលីហ្វ័រញ៉ា។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 39 បញ្ចប់ច្បាប់បញ្ចៀសពន្ធសំរាប់សាជីវកម្មក្រៅរដ្ឋ។

សំណើប្រជាមតិលេខ 39 គ្រាន់តែលុបបំបាត់ការបញ្ចៀសពន្ធនៃច្បាប់នេះ។ សំណើប្រជាមតិបញ្ឈប់ការបន្លំនៃប្រព័ន្ធពន្ធដាររបស់យើង - ហើយក៏តម្រូវឲ្យក្រុមហ៊ុនទាំងអស់ដែលធ្វើជំនួញនៅរដ្ឋ កាលីហ្វ័រញ៉ា បង់ពន្ធដូចដែលបានកំណត់ដោយការលក់របស់ពួកគេនៅទីនេះ ដោយមិនគិតពីមូលដ្ឋានដែលពួកគេតាំងនៅទេ។

សំណើប្រជាមតិលេខ 39 *ពង្រាបទីលានលេងឲ្យស្មើភាព* ធានាឲ្យក្រុមហ៊ុនពហុរដ្ឋទាំងឡាយលេងដោយប្រើប្រាស់ច្បាប់ដូចគ្នាទៅនឹងនិយោជកនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 39 បញ្ចប់ច្បាប់បញ្ចៀសពន្ធ គឺជាការល្អសំរាប់ទីផ្សារការងារនៅរដ្ឋកាលីហ្វ័រញ៉ា

ច្បាប់ការបញ្ចៀសពន្ធដារបច្ចុប្បន្ននេះអនុញ្ញាតឲ្យក្រុមហ៊ុនបង់ពន្ធតិចជាងមុនទៅឲ្យរដ្ឋកាលីហ្វ័រញ៉ា ប្រសិនបើពួកគេមាននិយោជិកតិចតួចនៅទីនេះ - ដែលផ្តល់ឲ្យក្រុមហ៊ុនទាំងឡាយនូវហេតុផលមួយក្នុងការបញ្ជូនការងារចេញពីរដ្ឋ។

ជាក់ស្តែង អ្នកវិភាគផ្នែកនីតិបញ្ញត្តិដែលគ្មានបក្សព័ន្ធ និងឯករាជ្យរបស់រដ្ឋបានទាញអំណះអំណាងពីការសិក្សា ដែលបង្ហាញថាគោលនយោបាយពន្ធដារនៅក្នុងសំណើប្រជាមតិលេខ 39 នឹងនាំមកឲ្យរដ្ឋ កាលីហ្វ័រញ៉ានូវការងារប្រមាណជា 40,000 ការងារ។ នោះគឺជាហេតុផល ដែលអ្នកវិភាគផ្នែកនីតិបញ្ញត្តិឯករាជ្យបានប្រកាសឲ្យលុបចោលច្បាប់ការបញ្ចៀសពន្ធបច្ចុប្បន្ននេះចេញ។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 39 មានប្រយោជន៏ដល់អ្នកជាប់ពន្ធនៅកាលីហ្វ័រញ៉ា

សាជីវកម្មពហុរដ្ឋដែលផ្តល់ការងារដ៏តិចតួចនៅទីនេះគឺបានប្រើច្បាប់បញ្ចៀសពន្ធដើម្បីជៀសវាងបង់ពន្ធចំណែកស្មើភាពរបស់គេដល់កាលីហ្វ័រញ៉ា វាបណ្តាលឱ្យអស់តំលៃដល់រដ្ឋ $1 មួយរយកោដិដុល្លារក្នុងមួយឆ្នាំ។ សំណើប្រជាមតិ 39 នឹងបិទការបញ្ចៀសពន្ធរបៀបនេះហើយរក្សាថវិកានោះនៅក្នុងរដ្ឋកាលីហ្វ័រញ៉ាសំរាប់ផ្តល់ជាប្រាក់ចំណូលដែលត្រូវការយ៉ាងសំខាន់សំរាប់សេវាសាធារណៈ។ ពីព្រោះប្រាក់ចំណូលថ្មីទាំងអស់ស្ទើរតែពាក់កណ្តាលគឺតម្រូវដោយច្បាប់ឲ្យចូលទៅក្នុងវិស័យអប់រំ ទឹកប្រាក់រាប់រយលានដុល្លារជារៀងរាល់ឆ្នាំ នឹងត្រូវបានតំកល់ ទុកសំរាប់សាលារៀន។

បន្ថែមលើនេះ សំណើប្រជាមតិលេខ 39 នឹងបង្កើតប្រាក់សន្សំសំរាប់ អ្នកជាប់ពន្ធជាច្រើន។ សំណើប្រជាមតិលេខ 39 នឹងប្រើប្រាស់មួយភាគនៃប្រាក់ចំណូលដែលបានមកពីការលុបបំបាត់ការគេចពីច្បាប់ដើម្បីផ្តល់មូលនិធិសម្រាប់គម្រោងប្រសិទ្ធភាពថាមពលមាននៅ សាលារៀន និងអគារសាធារណៈផ្សេងទៀត។ ប្រើប្រាស់វិធានការបង្ហាញពីប្រសិទ្ធភាពថាមពល ដូចជា ការកែលម្អ អ៊ីសូឡង់ ប្តូរបង្អួច និងដំបូលដែលលេចធ្លាយ និងការដាក់បន្ថែមការតំឡើងបន្ទះសូឡាស្រូបថាមពលព្រះអាទិត្យខ្នាតតូច នឹងកាត់បន្ថយការចំណាយថាមពលរបស់រដ្ឋ—បង្កើនចំនួនប្រាក់ដុល្លារសម្រាប់សេវាកម្មចាំបាច់ដូចជា ការអប់រំ ប៉ូលីស និងអគ្គីភ័យ។

*"ដោយការបង្កើនប្រសិទ្ធភាពថាមពល សំណើប្រជាមតិលេខ 39 នឹងកាត់បន្ថយការបំពុលបរិយាកាសដែលបណ្តាលឲ្យកើតជំងឺហឺត និងជំងឺសួត។ ក្នុងដំណើរការនៃការធ្វើបច្ចុប្បន្នភាពអគារសាលារៀន សំណើប្រជាមតិលេខ 39 នឹងបំបាត់ជាតិសំណ សារធាតុដែលមិនឆេះ សារធាតុផ្សិត និងសារធាតុពុលផ្សេងទៀតចេញពីសាលារៀន។"—*
Jane Warner, ប្រធាន, សមាគមសួតអាមេរិកាំង ក្នុងរដ្ឋកាលីហ្វ័រញ៉ា។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 39—គណនេយ្យភាពដ៏ហ្មត់ចត់

សំណើប្រជាមតិលេខ 39 មានខមាត្រាចែងអំពីការទទួលខុសត្រូវដ៏តឹងរឹងមួយ —រួមទាំងការធ្វើសវនកម្មប្រចាំឆ្នាំឯករាជ្យមួយ បន្តការពិនិត្យ និងការវាយតំលៃដោយក្រុមប្រឹក្សាគ្រប់គ្រងពលរដ្ឋ មានគណនេយ្យភាពគ្រប់សព្វសំរាប់ថវិកា និងការចំណាយនានា និងមានការបញ្ចេញជាសាធារណៈដែរ។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 39—ជារឿងសាមញ្ញមួយ៖ បិទការបញ្ចៀសពន្ធចេញទៅក្រៅរដ្ឋ។ នាំមកវិញនូវប្រាក់ មួយរយកោដិដុល្លារ ក្នុងមួយឆ្នាំ ត្រឡប់មកកាលីហ្វ័រញ៉ាវិញ។

*http://www.cleanenergyjobsact.com/*

**JANE WARNER,** ប្រធាន
សមាគមសួតអាមេរិកាំងនៅកាលីហ្វ័រញ៉ា

**TOM STEYER,** ប្រធាន
ពលរដ្ឋកាលីហ្វ័រញ៉ា សំរាប់ថាមពលស្អាត និងការងារ

**MARY LESLIE,** ប្រធាន
ក្រុមប្រឹក្សាពាណិជ្ជកម្ម Los Angeles

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 39 ★

ពេលណាអ្នកអានការសន្យាឃោសនាសំរាប់សំណើប្រជាមតិ 39 ត្រូវចាំថា Tom Steyer—ដែលទូរទស្សន៍ CNN ហៅគាត់ថា "ស្តេចមូលនិធិហេដ្ជរបស់កាលីហ្វ័រញ៉ា"—គឺចំណាយ $20 លានដុល្លារសំរាប់ ការបោះឆ្នោតសាកល្បងប្រើពាក្យដែលសូរស័ព្ទប្លែកដូចជាពាក្យ "ការបញ្ចៀសពន្ធ," ហើយសន្យា "ការងារស្អាត។"

កាលីហ្វ័រញ៉ាបានបាត់បង់ពាណិជ្ជកម្មតាមអត្រាគួរឱ្យសំគាល់រួចទៅហើយ។ សួរខ្លួនឯងថា តើការតំឡើងពន្ធលើក្រុមហ៊ុនបំរើការងារដល់ពលរដ្ឋកាលីហ្វ័រញ៉ារាប់រយពាន់នាក់ ធ្វើឱ្យសេដ្ឋកិច្ចគ្រាន់បើ ឬទេ?

វាមិនប្រសើរទេ!

កាលីហ្វ័រញ៉ាជំពាក់បំណុលរាប់កោដិរួចទៅហើយ តែសំណើប្រជាមតិ 39 នឹងធ្វើឱ្យអ្វីៗកាន់តែអាក្រក់ឡើង!

កាលីហ្វ័រញ៉ាគឺ*ជារដ្ឋមួយមិនល្អសំរាប់ការធ្វើជំនួញអស់រយៈកាល ប្រាំបីឆ្នាំជាប់ៗគ្នា* ហើយក៏វិតពិន្ទុក្រេឌីតអាក្រក់ជាងគេបំផុតក្នុងសហរដ្ឋអាមេរិក។ ពលរដ្ឋច្រើនលាននាក់ឥតការងារធ្វើ។

ការបញ្ចៀសពន្ធ? បោះឆ្នោត ទេ លើសំណើប្រជាមតិ 39 លប់ចោលច្បាប់ពន្ធដារដែលមានឥទ្ធិពលច្រើនទស្សវត្សបង្កើនថវិកាចំណូលរដ្ឋ។ អ្នកវិភាគអង្គនិតិបញ្ញត្តិមិនចូលបក្សព័ន្ធ និងក្រសួងហិរញ្ញវត្ថុយល់ស្របថា ៖ សំណើប្រជាមតិ 39 គឺកំណើនពន្ធដារ $1 មួយរយកោដិដុល្លារ។

នេះជាការពិត។ កំណើនពន្ធ $1 មួយរយកោដិដុល្លារផ្តល់ឱ្យនិយោជកកាលីហ្វ័រញ៉ានូវមូលហេតុមួយទៀត មិនឱ្យធ្វើវិនិយោគ ឬជួលអ្នកធ្វើការ។ ការងារតិចតួច មានន័យថា ប្រាក់ចំណូលក៏ទាប ហើយថវិកាសាលារៀន, និងអាជ្ញាធរមានសមត្ថកិច្ចក៏ត្រូវកាត់ច្រើនទៀត។ តើនេះវាល្អសំរាប់កាលីហ្វ័រញ៉ា ឬ?

39

សំណើប្រជាមតិ 39 គឺជាប្រអប់ឆ្នោត គិតគូរថវិកាដ៏អាក្រក់មួយរបស់វា។ វាឆក់យកថវិកា $2.5 ពីររយប្រាំកោដិពីថវិការដ្ឋ—ជាប្រាក់ដែលអាចជួយសាលារៀន សង់ផ្លូវ, ហេដ្ឋារចនាសម្ព័ន្ធ, ឬសុវត្ថិភាពសាធារណៈ។

សំណើប្រជាមតិ 39 ក៏បន្ថែមការិយាធិបតេយ្យថ្មីៗ—ផ្តល់រាប់លានដុល្លារជាបៀវត្សន៏ និងសោធននិវត្តន៏ដល់អ្នកនយោបាយ។ បក្សពួកគេ។ ក្មានការទទួលខុសត្រូវ ហើយគ្មានវិធានការការពារពលរដ្ឋជាប់ពន្ធប្រឆាំងនឹងអំពើពុករលួយ។

ពន្ធដារខ្ពស់, ការងារតិចតួច, ការិយាធិបតេយ្យច្រើន និងខ្ជះខ្ជាយ . . . ការទទួលខុសត្រូវ សូន្យ ឃើគ្មានការការពារពលរដ្ឋជាប់ពន្ធទល់នឹងការប្រទាំងផលប្រយោជន៏។ នេះហើយជារឿងរ៉ាវរបស់សំណើប្រជាមតិ 39។

បក្សប្រជាធិបតេយ្យ, បក្សឯករាជ្យ, បក្សសាធរណរដ្ឋ យល់ស្របតាមe—បោះឆ្នោត ទេ!

**MIKE SPENCE,** ប្រធាន
គណៈកម្មការការពារអ្នកជាប់ពន្ធកាលីហ្វ័រញ៉ា

**ROBERT MING,** ប្រធាន
មិត្តសំរាប់រក្សាការងារនៅកាលីហ្វ័រញ៉ា

**JACK STEWART,** ប្រធា
សមាគមឧស្សាហកម្ម និងបច្ចេកវិទ្យា កាលីហ្វ័រញ៉ា



ទឡ្ហីករណ៍បោះពុម្ពនៅក្នុងទំព័រនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យមើលភាពត្រឹមត្រូវដោយទីភ្នាក់ងារជាផ្លូវការណាមួយឡើយ។

# សំណើប្រជាមតិ 39 លក្ខខ័ណ្ឌពន្ធដារ សំរាប់ពាណិជ្ជកម្មពហុរដ្ឋ។ ការផ្តល់ថវិកាសំរាប់ថាមពលល្អស្អាត និងថាមពលបរិប្បូរណ៍។ លក្ខន្តិកៈផ្តួចផ្តើម។

## ★ ទទ្បហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 39 ★

សំណើប្រជាមតិលេខ 39 គឺជាកំណើនពន្ធដ៏ច្រើនសន្ធឹកមួយរយកោដិដុល្លារ មកលើអ្នកបង្កើតការងារនៅកាលីហ្វ័រញ៉ាដែលនឹងបណ្តាលឱ្យបាត់បង់ការងាររាប់ពាន់សំរាប់ជនថ្នាក់កណ្តាល។ អត្រាឥតការងារធ្វើក្នុងរដ្ឋកាលីហ្វ័រញ៉ាឡើងដល់កំរិតអាក្រក់ទីបីនៅក្នុងប្រទេស គឺជិតដល់កំរិត 11%។ សំណើប្រជាមតិលេខ 39 ធ្វើឱ្យបញ្ហារបស់យើងកាន់តែយ៉ាប់យ៉ឺនឡើង។

សំណើប្រជាមតិលេខ 39 គឺជាបង្កាន់ដៃសំរាប់ការខ្ជះខ្ជាយ និងពុករលួយ។ វាត្រូវចំណាយរហូតដល់ $22 លានសំរាប់ការិយាធិបតេយ្យថ្មី និងគណៈ កម្មការមានផលប្រយោជន៍ពិសេស។ វាផ្តល់ឱ្យអ្នកនយោបាយនៅ Sacramento នូវសន្លឹកសែកចំហរមួយចំណាយប្រាក់រាប់រយកោដិដោយគ្មានការទទួលខុសត្រូវពិតប្រាកដ ឬការការពារអ្នកជាប់ពន្ធដារទល់នឹងការប្រទាំងផលប្រយោជន៍ពិសេស។

ខាងក្រោមនេះជាអង្គហេតុ ៖ មហាសេដ្ឋីម្នាក់ដែលទូរទស្សន៍ CNN ហៅថា "ស្តេចមូលនិធិហេជ្សរបស់កាលីហ្វ័រញ៉ា" គឺនៅពីក្រោយចំណាយទឹកប្រាក់ជួយសំណើប្រជាមតិ 39, ចំណាយប្រាក់ $20 លានដុល្លារសំរាប់ជះឥទ្ធិពលលើការបោះឆ្នោតរបស់អ្នក និងទិញការបោះឆ្នោត។ អ្នកឱ្យឱវាទនយោបាយរបស់គាត់ប្រើវាក្យសព្ទដូចជា "បិទការបញ្ចៀសពន្ធ" តែកុំជឿពួកគេ។

សំណើប្រជាមតិលេខ 39 ជានយោបាយកំពុងធ្វើការ។ កាលីហ្វ័រញ៉ាត្រូវការកែទម្រង់ មិនមែនបង្កើនពន្ធ និងចំណាយខ្ជះខ្ជាយ។ យើងត្រូវតែបោះឆ្នោត ទេ។

ទឹកប្រាក់ $2.5 ពីររយប្រាំកោដិដុល្លារ ដែលអាចចូលទៅសាលារៀន,សុខាភិបាល និងសង្គមកិច្ច, ការពារបរិស្ថាន ឬសុវត្ថិភាពសាធារណៈជាជាងបង្វែរវាទៅឱ្យគណៈកម្មការរដ្ឋាភិបាលថ្មីមួយ ជាមួយនឹងប្រាក់ខែធាត់ៗ ហើយមានការទទួលខុសត្រូវតិច។ ឱនភាពនៃថវិការដ្ឋរបស់យើងថ្ងៃនេះជិតដល់កំរិត $16 មួយពាន់ប្រាំមួយរយកោដិ ហើយសំណើប្រជាមតិលេខ 39 ធ្វើឱ្យការនេះកាន់តែអាក្រក់ថែមទៀតដោយការការចំណាយខ្ជះខ្ជាយលើការិយាធិបតេយ្យដែលពុំចាំបាច់។

កាលីហ្វរញ៉ាត្រូវការគ្រូបង្រៀន និងភ្នាក់ងារប៉ូលីស មិនត្រូវការអ្នកការិយាធិប តេយ្យទៀតទេ!

សំណើប្រជាមតិលេខ 39 វាយប្រហារពាណិជ្ជកម្មដែលផ្តល់ការងារថ្នាក់មធ្យមដល់ពលរដ្ឋកាលីហ្វ័រញ៉ា។ ការងារឧស្សាហកម្មដែលផ្តល់ដល់គ្រួសារគឺត្រូវរលាយបាត់អស់។ ពលរដ្ឋកាលីហ្វ័រញ៉ាធ្វើការធូន់ជិតពីរលាននាក់គឺកំពុងជួបប្រទះការលំបាករកងារគ្រប់ប្រភេទធ្វើ។ ប្រាក់ $1 មួយរយកោដិដុល្លារដែលជាកំណើនពន្ធដោយសំណើប្រជាមតិលេខ 39 ប្តូរច្បាប់ពន្ធដារដែលកំពុងមានឥទ្ធិពលជាង 40 ឆ្នាំ ហើយវា និងត្រូវអស់ថ្លៃច្រើនដល់ការងារកម្មករសហជីព និង មិនសហជីព។

សំណើប្រជាមតិលេខ 39 ពង្រីករដ្ឋាភិបាល និង ការិយាធិបតេយ្យ។ អ្នកបានឮពីមុនរួចមកហើយ។ Sacramento មានផែនការបង្កើតការងារ។ យើងផ្តល់ប្រាក់ឱ្យគេបង្កើតគណៈកម្មការនយោបាយចាត់តាំងមួយជាមួយនឹងឈ្មោះដែល ចាប់អារម្មណ៍ដូចជា ក្រុមប្រឹក្សាគ្រប់គ្រងពលរដ្ឋ។ ពួកគេទទួលសន្លឹកសែកចំហរដើម្បីចំណាយ(ឬខ្ជះខ្ជាយ) ប្រាក់ពន្ធ។

ក្រោមសំណើប្រជាមតិលេខ 39 ប្រាក់ត្រូវចំណាយដើម្បីផ្តលកុងត្រាទៅកម្មវិធីដែលហៅថា "ថាមពលបៃតង"។ តើនរណាទំនងជាទទួលបានកុងត្រានេះ? អ្នកធ្វើវិភាគទានយុទ្ធនាការឃោសនាធំៗ ដែលសរសេរតាក់តែង សំណើប្រជាមតិលេខ 39 យ៉ាងអាក្រក់បំផុត សំណើនោះមិនមានហាមឃាត់អ្នកម៉ៅការពីការធ្វើវិភាគទានថវិកាឃោសនាទៅឱ្យអ្នកនយោបាយ SACRAMENTO ដែលផ្តល់កុងត្រានោះឱ្យ។

កាលីហ្វ័រញ៉ាត្រូវការកែទម្រង់, មិនមែនបង្កើនពន្ធដែលបំបាត់ការងារថ្នាក់កណ្តាលនោះទេ។ សំណើប្រជាមតិលេខ 39 តំឡើងពន្ធ $1 មួយរយកោដិដុល្លារលើអ្នកបង្កើត ការងារនៅកាលីហ្វ័រញ៉ាដើម្បីផ្តល់ថវិកាសំរាប់ការិយាធិបតេយ្យក្នុងរដ្ឋាភិបាលកាន់តែ ច្រើននិងបំប៉ោងប្រាក់សោធននិវត្តន៍ថែមទៀត។ វាមិនការពារទប់ទល់នឹងឧនភាពដែលរដ្ឋកំពុងតែជួបប្រទះ, ភាពឥតការងារធ្វើខ្ពស់, និងបន្តសេដ្ឋកិច្ចធ្លាក់ចុះ។

ចងចាំថា មហាសេដ្ឋីម្នាក់មានរបៀបវារៈរបស់ខ្លួនកំពុងនៅពីក្រោយចេញប្រាក់ជួយសំណើប្រជាមតិលេខ 39។ ជាស្រេចតែឆន្ទៈអ្នកបោះឆ្នោតទេក្នុងការការពារពលរដ្ឋជាប់ពន្ធនៅកាលីហ្វ័រញ៉ា។ ដោយបោះឆ្នោត ទេ លើសំណើប្រជាមតិលេខ 39។ អ្នកនឹងបញ្ឈប់ការសំឡាប់ការងារនៃប្រាក់ពន្ធកំណើន $1 មួយរយកោដិដុល្លារលើអ្នកបង្កើតការងារនៅកាលីហ្វ័រញ៉ា។ អ្នកនឹងគាំទ្រការងារថ្នាក់មធ្យមនៅកាលីហ្វ័រញ៉ាដែល ផ្តល់ដល់គ្រួសារនឹងទ្រទ្រង់ដល់សេដ្ឋកិច្ចយើង។ ហើយអ្នកនឹងប្រាប់អ្នកនយោបាយ Sacramento ថា គ្មានសន្លឹកសែកចំហរសំរាប់ក្រុមមានផលប្រយោជន៍ពិសេស សំរាប់ចំណាយលើការបំប៉ោងរដ្ឋាភិបាល និងសោធននិវត្តន៍របស់គ។

និយាយថា ទេ ទល់នឹងពន្ធដារខ្ពស់ ការចំណាយខ្ជះខ្ជាយ និងនយោបាយជាធម្មតា។ តំរូវឱ្យមានការទទួលខុសត្រូវពីរដ្ឋាភិបាល។ បោះឆ្នោត ទេ សំណើប្រជាមតិលេខ 39។

**JACK STEWART,** ប្រធាន
សមាគមឧស្សាហកម្ម និងបច្ចេកវិទ្យា កាលីហ្វ័រញ៉ា

**LEW UHLER,** ប្រធាន
គណៈកម្មាធិការកំរិតពន្ធដារជាតិ

**PAT FONG KUSHIDA,** ប្រធាន
សភាពាណិជ្ជកម្មអាស៊ីប៉ាស៊ីហ្វិក កាលីហ្វ័រញ៉ា

## ★ ការឆ្លើយបដិសេធលើទទ្បហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 39 ★

អង្គហេតុ ៖ បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 39 បិទការបញ្ចៀសពន្ធសំរាប់សាជីវកម្មក្រៅរដ្ឋ។

ទទ្បហីករណ៍ប្រឆាំងគឺមានភាពបោកបញ្ឆោតគួរឲ្យខ្មាស់។ សំណើប្រជាមតិលេខ 39 មិនបានតំឡើងពន្ធទៅលើគ្រួសារដែលរស់នៅរដ្ឋកាលីហ្វ័រញ៉ា សូម្បីតែមួយសេន។ សំណើប្រជាមតិនេះគ្រាន់តែលុបបំបាត់ការគេចពីច្បាប់ដែលផ្តល់ឲ្យក្រុមហ៊ុននៅក្រៅរដ្ឋនូវការលើកលែងពន្ធដែលអយុត្តិធម៌ ប៉ុន្តែដាក់បន្ទុកចំណាយដល់យើងទាំងអស់គ្នា។

ដូច្នេះហើយទើបក្រុមហ៊ុននៅក្រៅរដ្ឋនានា—រួមបញ្ចូលក្រុមហ៊ុននានា ដែលគ្រប់ដណ្តប់ "ក្រុមអ្នកផលិត" ដែលបានចុះហត្ថលេខាលើទទ្បីករណ៍ខាងលើ—កំពុងធ្វើការឃោសនាបោកបញ្ឆោតប្រឆាំងទៅនឹងសំណើប្រជាមតិលេខ 39: ដើម្បីរក្សាទុកនូវច្បាប់ការបញ្ចៀសពន្ធដដែល។
អង្គនិតិបញ្ញត្តិ និងក្រុមតស៊ូមតិបង្កើតការបញ្ចៀសពន្ធនេះក្នុងកិច្ចព្រមព្រាងសំងាត់កាលពីឆ្នាំ 2009។

ព័ត៌មាន San Jose Mercury បាននិយាយថាអ្នកបញ្ចុះបញ្ចូលរបស់ក្រុមហ៊ុន "បានទាញយ៉ាងលឿននៅរដ្ឋកាលីហ្វ័រញ៉ា" ហើយថា "វាជាប្រភេទនៃការបោកបាស់ដែលផ្តល់ឲ្យក្រុមហ៊ុននូវកេរ្តិ៍ឈ្មោះអាក្រក់ ហើយធ្វើឲ្យមានការចំអកដល់ភាពបើកចំហរបស់រដ្ឋាភិបាល។"

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 39 លុបបំបាត់ច្បាប់បញ្ចៀសពន្ធបោសសម្អាតភាពរញ៉េរញ៉ៃដែលអង្គនីតិបញ្ញត្តិបានបង្កើតឡើង។
អង្គហេតុ ៖ សំណើប្រជាមតិលេខ 39 បង្កើតការងារនៅកាលីហ្វ័រញ៉ា

ទទ្បហីករណ៍ប្រឆាំងអំពីការយកពន្ធពីនិយោជកគឺជាការកំប្លែងមួយ។ ច្បាប់បញ្ចៀសពន្ធគឺមានផលប្រយោជន៍ដល់សាជីវកម្មដែលរក្សាការងារក្រៅរដ្ឋ។

សំណើប្រជាមតិលេខ 39 នឹងលុបបំបាត់ឧបសគ្គក្នុងការ បង្កើតការងារក្នុងរដ្ឋកាលីហ្វ័រញ៉ា។ លើសពីនេះ សំណើប្រជាមតិលេខ 39 បានបង្កើតការងារថាមពលស្អាតរាប់ពាន់ទៀត។
អង្គហេតុ ៖ តំរូវឱ្យមានការទទួលខុសត្រូវហ្មត់ចត់បំផុត

ទទ្បហីករណ៍ប្រឆាំងដែលក្លែងក្លាយអំពីការិយាធិបតេយ្យគឺគ្មានន័យ។ សំណើប្រជាមតិលេខ 39 បង្កើតគណៈកម្មការក្រុមប្រឹក្សាប្រជាពលរដ្ឋដើម្បីធានាថាថវិកាដែលបានបរិច្ចាគសំរាប់តែការបង្កើតការងារនិងប្រសិទ្ធិភាពថាមពល ត្រូវបានចំណាយយ៉ាងត្រឹមត្រូវ រាប់បញ្ចូលទាំងការធ្វើសវនកម្មឯករាជ្យប្រចាំឆ្នាំ។ សាលារៀននឹងទទួលបានទឹកប្រាក់រាប់រយលាននៅក្នុងការផ្គត់ផ្គង់ថវិកា ដែលបានកំណត់ទុក ពោលបានពីការលុបបំបាត់ច្បាប់បញ្ចៀសពន្ធ។
បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិលេខ 39 បិទច្បាប់បញ្ចៀសពន្ធ—រក្សាទុកប្រាក់ដុល្លារ និងការងារក្នុងរដ្ឋកាលីហ្វ័រញ៉ា។

**ALAN JOSEPH BANKMAN,** សាស្ត្រាចារ្យ ច្បាប់ផ្នែកពន្ធដារ
សាលាច្បាប់ Stanford

**RUBEN GUERRA,** CEO
សមាគមពាណិជ្ជកម្មឡាទីណូ

**JANE SKEETER**
ម្ចាស់អាជីវកម្មខ្នាតតូច កាលីហ្វ័រញ៉ា